# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ００២/១៩-០៩-២００៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Nov-2019, 15:27
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
## ចំពោះសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រមម្នាក់នៃអង្គជំនុំជម្រះតុលាការកំពូល

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Megan HIRST

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

**នៅចំពោះមុខ៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE-MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

Original EN:

សំ សុគង់

វ៉ើន ពៅ

ទី ស្រ៊ីនណា

Olivier BAHOUGNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang LIU
Daniel LOSQ
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Mahesh RAI

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Brenda J. HOLLIS

**ជនជាប់ចោទ៖**

ខៀវ សំផន

**សហមេធាវីការពារក្តី៖**

គង់ សំអុន

Anta GUISSÉ

# I. សេចក្តីផ្តើម

1. អនុលោមតាម សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យារពេលដាក់សារណាតបទៅនឹងសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រមបួនរូប ដែលសម្រេចដោយ អង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩[1] សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមឆ្លើយតបចំពោះសំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូល ដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១ ("សំណើសុំប្តឹងជំទាស់" ឬ "សំណើ")[2]។ នៅក្នុងសំណើ មេធាវីការពារក្តី ខៀវ សំផន ("មេធាវីការពារក្តី") បានស្នើសុំប្តឹងជំទាស់ចៅក្រមប្រាំមួយរូបក្នុងចំណោមក្រុមប្រឹក្សាចៅក្រមទាំងប្រាំពីររូបនៃអង្គជំនុំជម្រះតុលាការកំពូល ចេញពីកិច្ចដំណើរការនីតិវិធីបន្តនៃសំណុំរឿង ០០២/០២[3] គឺ ចៅក្រមទាំងប្រាំមួយរូបដែលបានសម្រេចសេចក្តីក្នុង បណ្តឹងសាទុក្ខសំណុំរឿង ០០២/០១[4]។

2. សហមេធាវីនាំមុខកម្រិតចម្លើយតបរបស់ខ្លួនតែត្រឹមភាពអាចទទួលយកបាននៃសំណើ ដោយសារតែក្តីបារម្ភយ៉ាងខ្លាំងទាក់ទងនឹងភាពឆាប់រហ័ស និងសុវត្ថិភាពគតិយុត្តិ ដែលបញ្ហានៃភាពអាចទទួលយកបាននៃសំណើលើកឡើងនេះ នាំឲ្យប៉ះពាល់ខ្លាំងចំពោះផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណី។ សំណើត្រូវបានដាក់នៅក្រៅក្របខណ្ឌពេលវេលាដែលបានអនុញ្ញាតតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្តីបានដឹងអំពីមូលដ្ឋាននៃសារណានេះ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៦។

---

[1] ឯកសារ **F53/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យារពេលដាក់សារណាតបទៅនឹងសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ កថាខណ្ឌ ១៣។

[2] ឯកសារ **F53** សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ចៅក្រម ៦ រូប នៃអង្គជំនុំជម្រះតុលាការកំពូល ដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ថ (ត្រូវបានជូនដំណឹងនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩) ["សំណើសុំប្តឹងជំទាស់"]។

[3] តាមពិតទៅ សំណើមិនបានបញ្ជាក់លម្អិតថា កិច្ចដំណើរការនីតិវិធីណាមួយ ដែលសំណើចាត់ទុកថា បានទទួលរងផលប៉ះពាល់ដោយសារតែភាពលម្អៀងដែលបានចោទប្រកាន់ ប៉ុន្តែ ហាក់ដូចជាមានគោលដៅសំដៅទៅលើការប្តឹងជំទាស់ទាំងស្រុងចំពោះចៅក្រមទាំងអស់នេះ ចេញពីកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២ ទាំងអស់។

[4] មិនមានសំណើសុំប្តឹងជំទាស់ចៅក្រម Harding Clark ដែលត្រូវបានតែងតាំងជាចៅក្រមអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងខែសីហា ឆ្នាំ២០១៩ គឺនៅក្រោយពេលបញ្ចប់បណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១។

មេធាវីការពារក្ដីគួរតែដាក់សំណើភ្លាមៗ នៅពេលដែលកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខបានចាប់ផ្ដើមដំបូងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។ ផ្ទុយទៅវិញ មេធាវីការពារក្ដីបានដាក់សារណាជាច្រើនផ្សេងៗគ្នា ជាបន្តបន្ទាប់ជូនទៅចៅក្រមដែលខ្លួនសុំប្ដឹងជំទាស់ចិត្តនាពេលនេះ ដោយមេធាវីការពារក្ដីព្យាយាមស្វែងរកលទ្ធផលដែលពួកគេអាចប្រើជាភស្តុតាងស្ដីពីភាពលម្អៀង។ ការធ្វើបែបនេះគឺជាការរំលោភបំពានយ៉ាងច្បាស់លាស់ទៅលើនីតិវិធីនៃ វិធាន ៣៤ របស់វិធានផ្ទៃក្នុង។

3. លើសពីនេះទៀត ខុសពីកាលៈទេសៈដែលកើតឡើងនៅក្នុងឆ្នាំ ២០១៤ ដែលពេលនោះមានការលើកឡើងពីការជំទាស់ពាក់ព័ន្ធនឹងអនាគតិរបស់អង្គជំនុំជម្រះសាលាដំបូង ករណីបច្ចុប្បន្ននេះ ផលប្រយោជន៍យុត្តិធម៌គឺជាមូលដ្ឋានគាំទ្រយ៉ាងខ្លាំងដល់ការច្រានចោលសំណើ ដោយមូលហេតុថាមិនអាចទទួលយកបាន។

## II. សិទ្ធិ

4. ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការឆ្លើយតបចំពោះពាក្យសុំ នៅក្នុងដំណាក់កាលបណ្ដឹងសាទុក្ខនៃកិច្ចដំណើរការនីតិវិធី[5] កាលណាពាក្យសុំនោះប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី[6]។ ដូចពន្យល់បន្ថែមនៅផ្នែកខាងក្រោម (សូមមើលផ្នែក III(២)ខ ខាងក្រោម) ដើមបណ្ដឹងរដ្ឋប្បវេណីមិនគ្រាន់តែមានផលប្រយោជន៍ខាង "សុវត្ថិភាពគតិយុត្តិ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព" (វិធាន ២១(១) នៃវិធានផ្ទៃក្នុង) ប៉ុណ្ណោះទេ ប៉ុន្តែ

[5] ឯកសារ F10/2 សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៤, ១៧ ("សេចក្ដីសម្រេចលើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី") ("សេចក្ដីសម្រេចលើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី")។ សេចក្ដីសម្រេចលើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដោះស្រាយចំពោះសិទ្ធិក្នុងការឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីជាពិសេស។ គោលការណ៍ដែលលើកឡើងនៅក្នុងកថាខណ្ឌ ១៤ និង១៧ នៃសេចក្ដីសម្រេចនោះ ត្រូវអនុវត្តចំពោះចម្លើយតបដទៃទៀត។ សូមមើល ឯកសារ F36 សាលដីកា ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១ ("នៅក្នុងសំណើនេះ អង្គជំនុំជម្រះយល់ស្របជាមួយ នួន ជា ត្រង់ចំណុចដែលថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពុំបានផ្ដល់មូលដ្ឋានគាំទ្រ ថាតើសារណារបស់ខ្លួន ស្របតាមគោលការណ៍ដូចបានកំណត់នៅក្នុងយុត្តិសាស្ត្រមុនៗយ៉ាងដូចម្ដេចឡើយ ដូចជា ថាតើសំណើរបស់ នួន ជា មានផលប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ខ្លួនយ៉ាងដូចម្ដេចឡើយ។ ការគ្រាន់តែយោងទៅលើភាពចាំបាច់ដើម្បីធានាបាន "តុល្យភាពរបស់ភាគី" មានលក្ខណៈជាទូទៅ ពុំអាចបំពេញតាមលក្ខខណ្ឌតម្រូវ បើទោះបីជាដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានសាលក្រមទាន់ពេលវេលាក៏ដោយ")។

[6] ឯកសារF10/2 សេចក្ដីសម្រេចលើសំណើរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៧។

ដើមបណ្ដឹងរដ្ឋប្បវេណីថែមទាំងត្រូវទទួលផលប្រយោជន៍ពីកិច្ចដំណើរការនីតិវិធីដែលឆាប់រហ័សទៀតផង។ វិធាន ២១(១) នៃវិធានផ្ទៃក្នុងកំណត់ថា ត្រូវគោរពសិទ្ធិរបស់ជនរងគ្រោះទាំងអស់នេះនៅគ្រប់ពេលក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល។

## III. សារណា

5. សហមេធាវីនាំមុខសូមលើកឡើងថា (១) សំណើសុំប្តឹងជំទាស់ត្រូវបានដាក់យឺតយ៉ាវខ្លាំង (២) ក្នុងករណីដូចនេះ ផលប្រយោជន៍នៃយុត្តិធម៌ផ្តល់ការគាំទ្រដល់ការច្រានចោល "សំណើ" ដោយសារតែសំណើមិនអាចទទួលយកបាន។

### (១) សំណើត្រូវបានដាក់យឺតយ៉ាវខ្លាំង

6. នៅមុនពេលធ្វើការវាយតម្លៃថា តើសំណើសុំប្តឹងជំទាស់ ត្រូវបានដាក់យឺតយ៉ាវដែរឬទេ និងតើយឺតដល់កម្រិតណានោះ ជាការចាំបាច់ត្រូវបកស្រាយដោយត្រឹមត្រូវទៅលើបទប្បញ្ញត្តិច្បាប់ដែលកំណត់ ពីពេលវេលាដែលត្រូវដាក់សំណើសុំប្តឹងជំទាស់។ បន្ទាប់ពីបកស្រាយដោយត្រឹមត្រូវរួចហើយ សហមេធាវីនាំមុខនឹងពិភាក្សាអំពីអត្ថិភាព និងកម្រិតនៃការយឺតយ៉ាវនៅក្នុងករណីនេះ។

### *ក. ពេលវេលាដែលត្រូវដាក់សំណើសុំប្តឹងជំទាស់ អនុលោមតាមវិធានផ្ទៃក្នុង*

7. វិធាន ៣៤ នៃវិធានផ្ទៃក្នុង បានកំណត់ពីនីតិវិធីក្នុងការប្តឹងជំទាស់ចៅក្រម។ កថាខណ្ឌ (៣) ចែងថា "ពាក្យបណ្តឹងត្រូវធ្វើឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ"។ កថាខណ្ឌ (៤)(ឃ) បានកំណត់ជាពិសេស អំពីបណ្តឹងជំទាស់ចំពោះចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ដែលចែងថា ក្នុងករណីដែលបញ្ហាបានកើតឡើង នៅមុនពេលបណ្តឹងសាទុក្ខ "ពាក្យបណ្តឹងជំទាស់ដែលអាចទទួលយកបានត្រូវតែធ្វើឡើង [...] នៅពេលចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ"។

8. មានការកំណត់ច្បាស់លាស់ថា លក្ខខណ្ឌតម្រូវទាំងពីរនេះត្រូវបានបង្កើតឡើងជាមួយគ្នា ដោយត្រូវបំពេញតាមលក្ខខណ្ឌទាំងពីរ[7]។ សហមេធាវីនាំមុខសូមលើកឡើងថា ការកំណត់នេះគឺដោយសារ

---

[7] **ឯកសារលេខ ៨** សេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១២ (ឯកសារភ្ជាប់ ១)។ **ឯកសារលេខ** 1/4 សេចក្តីសម្រេចលើ សំណើរបស់ អៀង ធីរិទ្ធ សុំប្តឹងជំទាស់ចៅក្រម សោម សិរីវឌ្ឍ ដោយសារមិនមានភាពឯករាជ្យ ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៤ (ឯកសារភ្ជាប់ ២)។

តែកថាខណ្ឌនីមួយៗមានតួនាទីផ្ទាល់រៀងខ្លួន ក្នុងការធានាអំពីលក្ខខណ្ឌតម្រូវសម្រាប់ភាពឆាប់រហ័ស[8]។

9. វិធាន ៣៥(៤)(ឃ) យោងទៅឃ្លា "នៅពេលចាប់ផ្តើមនីតិវិធីបណ្តឹងសាទុក្ខ" ដើម្បីជៀសវាងការដាក់សំណើសុំប្តឹងជិតចិត្ត ដែលរង់ចាំបណ្តឹងសាទុក្ខ ដែលអាចនឹងមិនកើតឡើង។ ចំណុចនេះត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងដីកាសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងឆ្នាំ២០១១ ទាក់ទងនឹងសំណើសុំប្តឹងជិតចិត្តចៅក្រម សោម សិរីវឌ្ឍ ("ដីកាសម្រេចលើចៅក្រម សោម សិរីវឌ្ឍ") ដោយដីកាសម្រេចនេះយោងទៅវិធាន ៣៥(៤)(ឃ) នៃវិធានផ្ទៃក្នុងដូចតទៅ៖

> ស្របជាមួយលក្ខខណ្ឌតម្រូវដែលថា ម្ចាស់ពាក្យសុំត្រូវមានផលប្រយោជន៍គតិយុត្តិ ដែលអាចរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ (បន្ទុកធ្ងន់ធ្ងរ) ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលមិនពិចារណាទៅលើអង្គសេចក្តីនៃសំណើសុំប្តឹងជិតចិត្តរបស់ម្ចាស់ពាក្យសុំទេ[9]។

ហេតុដូច្នេះ វិធាន ៣៥(៤)(ឃ) នៃវិធានផ្ទៃក្នុង មានគោលដៅជៀសវាងការដោះស្រាយបញ្ហាចោទប្រកាន់ពីភាពលម្អៀងដែលនៅតែជាសម្មតិកម្មនៅឡើយ ព្រោះចៅក្រមដែលរងការចោទប្រកាន់អាចនឹងមិនទទួលបណ្តឹងសាទុក្ខដែលប៉ះពាល់ដោយសារការចោទប្រកាន់អំពីភាពលម្អៀងនោះ។

10. ម្យ៉ាងទៀត វិធាន ៣៥(៤)(ឃ)នៃវិធានផ្ទៃក្នុងមានគោលដៅធានាភាពឆាប់រហ័ស និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីតុលាការ តាមវិធីដោយផ្ទាល់មួយ គឺថា នៅពេលដែលការចោទប្រកាន់អំពីភាពលម្អៀងដែលពាក់ព័ន្ធ លែងជាបញ្ហានៃសម្មតិកម្មទៀតហើយនោះ បញ្ហានេះចាំបាច់ត្រូវតែលើកឡើងភ្លាមៗ។ ការធ្វើបែបនេះធ្វើឲ្យការចោទប្រកាន់អំពីភាពលម្អៀង អាចត្រូវបានដោះស្រាយ នៅមុនពេលដែលអាចបង្កផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធី។ លើសពីនេះទៀត ប្រសិនបើ

---

[8] តម្រូវដោយមាត្រា ៣៣ *ថ្មី* និងមាត្រា ៣៧ *ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារ F49 សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ កថាខណ្ឌ ១៩។

[9] **ឯកសារលេខ** 1/4 សេចក្តីសម្រេចលើ សំណើរបស់ អៀង ធីរិទ្ធ សុំប្តឹងជិតចិត្តចៅក្រម សោម សិរីវឌ្ឍ ដោយសារមិនមានភាពឯករាជ្យ ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៥។ សូមមើលបន្ថែមខាងក្រោម។

ចៅក្រមថ្មីមួយរូបឬច្រើនរូប ត្រូវទទួលការតែងតាំង បញ្ហានេះអាចដោះស្រាយបានក្នុងពេលឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

11. លក្ខណៈសំខាន់នៃលក្ខខណ្ឌតម្រូវតាមវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុងសម្រាប់ការដាក់បណ្តឹងជំទាស់ចិត្ត ឲ្យបានឆាប់រហ័សបំផុតនោះ ត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូង នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តី អៀង សារី ដាក់សំណើសុំប្តឹងជំទាស់ចិត្តនៅមុនពេលវេលាដែលបានចែងនៅក្នុងវិធាន ៣៤(៤) នៃវិធានផ្ទៃក្នុង។ នៅពេលនោះ មុនពេលមានវិសោធនកម្មវិធានផ្ទៃក្នុង វិធាន ៣៤(៤)(គ) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានចែងថា សំណើសុំប្តឹងជំទាស់ចិត្ត "ពាក់ព័ន្ធទៅនឹងបញ្ហាមុនពេលជំនុំជម្រះ" ត្រូវដាក់ "នៅពេលសវនាការបឋម"[10]។ ទោះជាយ៉ាងនេះក៏ដោយ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យសំណើសុំប្តឹងជំទាស់ចិត្តអាចដាក់ជូនទៅអង្គជំនុំជម្រះ នៅមុនសវនាការបឋមបាន។ ដោយយោងទៅលក្ខខណ្ឌតម្រូវនៅក្នុងវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង ដែលថា សំណើសុំបែបនេះត្រូវធ្វើឡើង "ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនេះ" អង្គជំនុំជម្រះបានបញ្ជាក់ថា "ក្នុងន័យនៃកាតព្វកិច្ចនៃការយកចិត្តទុកដាក់ហ្មត់ចត់របស់គូភាគី និងដើម្បីផលប្រយោជន៍នៃការរៀបចំការជំនុំជម្រះក្តីប្រកបដោយប្រសិទ្ធភាព ពាក្យសុំនេះគប្បីត្រូវយកមកសម្រេចឲ្យបានឆាប់រហ័ស"[11]។

12. សំអាងហេតុនេះអាចអនុវត្តបានដូចគ្នាចំពោះកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ ប្រសិនបើបានដឹងពីមូលហេតុនៃការប្តឹងជំទាស់ចិត្ត នៅមុនពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានទទួលសំណុំរឿងជាផ្លូវការ វាមិនត្រឹមតែអាចដាក់សំណើសុំប្តឹងជំទាស់ចិត្តប៉ុណ្ណោះទេ ប៉ុន្តែវាកាន់តែប្រសើរបើសិនជាបានដាក់។ មូលហេតុនៅពីក្រោយវិធាន ៣៤(៤) នៃវិធានផ្ទៃក្នុង និងសំអាងហេតុនៃសេចក្តីសម្រេចលើចៅក្រម សោម សិរីវឌ្ឍ អាចត្រូវបានបំពេញ ប្រសិនបើកិច្ចដំណើរការនីតិវិធីបានឈានដល់ដំណាក់កាលមួយដែលមានភាពច្បាស់ថា បណ្តឹងសាទុក្ខត្រូវបានដាក់ ជាពិសេសបណ្តឹងសាទុក្ខដែលទទួលរងផលប៉ះពាល់ ដោយសារភាពលម្អៀងដែលបានចោទប្រកាន់។ ចាប់ពីចំណុចនោះមក បណ្តឹងសាទុក្ខ និងបញ្ហាលម្អៀង លែងជាសម្មតិកម្មទៀតហើយ

---

[10] *សូមមើល* វិធានផ្ទៃក្នុង វិសោធនកម្មលើកទី៦ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០។

[11] ឯកសារ **E5/3** សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ ២។

ប៉ុន្តែជាចំណុចពាក់ព័ន្ធពិតប្រាកដដល់ផលប្រយោជន៍របស់ម្ចាស់បណ្តឹងសាទុក្ខ។ សហមេធាវីនាំមុខលើកឡើងថា នេះគឺជាចំណុចដើមដំបូងបំផុតដែលសំណើអាចទទួលយកបាន។

13. ផ្ទុយទៅវិញ ចំណុចចុងក្រោយបំផុត ដែលសំណើសុំអាចត្រូវបានធ្វើឡើង ដើម្បីស្នើសុំដកចៅក្រមអង្គជំនុំជម្រះតុលាការកំពូលគឺ “នៅពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ”។ នៅពេលដែលកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ បានចាប់ផ្តើមហើយ ចាំបាច់ត្រូវតែដាក់សារណា ដើម្បីគោរពទៅតាមលក្ខខណ្ឌតម្រូវរបស់វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង ដែលតម្រូវឲ្យដាក់សំណើ “ឆាប់បំផុត” នៅពេលណាដែលភាគីបានដឹងអំពីមូលដ្ឋានដែលចោទជាបញ្ហានេះ។ ចំណុចនេះបង្ហាញច្បាស់ថា សារណាបែបនេះចាំបាច់ត្រូវដាក់ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលដែលដំណើរការនីតិវិធីបណ្តឹងសាទុក្ខបានចាប់ផ្តើម។ ការបកស្រាយឃ្លា “ពេលចាប់ផ្តើម” នៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ថាគ្របដណ្តប់ទៅលើរយៈពេលរាប់ខែ ឬរាប់ឆ្នាំ (ឬជាឧទាហរណ៍ រយៈពេលទាំងអស់នៅមុនពេលដាក់សារណាបណ្តឹងសាទុក្ខ[12]) គឺជាការមិនបានគិតគូរទាំងទៅលើន័យត្រង់ និងចេតនាច្បាស់លាស់របស់វិធាន៣៤(៣) នៃវិធានផ្ទៃក្នុង។

14. ហេតុដូច្នេះ សហមេធាវីនាំមុខសូមលើកឡើងថា ក្នុងករណីដែលភាគីបានដឹងអំពីបញ្ហានៃភាពលម្អៀង ដែលបានកើតឡើងមុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ៖

(១) ភាគី *អាច* ដាក់សំណើសុំប្តឹងដិតចិត្ត ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ចាប់ពីពេលដែលភាគីបានដឹងពីតម្រូវការក្នុងការប្តឹងសាទុក្ខ ដែលទទួលរងផលប៉ះពាល់ ដោយសារភាពលម្អៀងដែលបានចោទប្រកាន់ និង

(២) ដើម្បីអាចទទួលយកបាន ភាគីត្រូវតែដាក់សំណើភ្លាមៗ (ក្នុងរយៈពេល២ខែ) នៅពេលដែលកិច្ចដំណើរការនីតិវិធី បានចាប់ផ្តើមឡើង។

15. ជាចុងក្រោយ សហមេធាវីនាំមុខសូមលើកឡើងថា ដើម្បីគាំទ្រដល់គោលដៅនៃវិធាន ៣៤ នៃវិធានផ្ទៃក្នុង ឃ្លា “កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ” នៅក្នុងបរិបទនេះ គួរយកក្នុងន័យទូលាយដោយគ្របដណ្តប់ទៅលើនីតិវិធីទាំងឡាយណាដែលសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល ទទួលបណ្តឹង ដូចជា បណ្តឹងសាទុក្ខភ្លាមៗ បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងសាលក្រមនៃអង្គជំនុំជម្រះសាលា

[12] ការបកស្រាយនេះត្រូវបានលើកឡើងដោយមេធាវីការពារក្តីនៅក្នុង ជើងទំព័រ ២២ នៃសំណើសុំប្តឹងដិតចិត្ត។

ដំបូង និងការដាក់ឯកសារក្នុងអំឡុងពេលនៃនីតិវិធី ដែលពាក់ព័ន្ធជាមួយនឹងកិច្ចដំណើរការនីតិវិធីទាំងពីរប្រភេទនេះ។ ការបកស្រាយបែបនេះជាការចាំបាច់ ដើម្បីធានាថា ចៅក្រមមួយត្រូវបានសម្រេចថាបាត់បង់សមត្ថកិច្ចក្នុងការចូលរួមធ្វើសេចក្តីសម្រេចណាមួយដែលពាក់ព័ន្ធ ឱ្យនាប់រហ័ស ព្រោះមានភាពលម្អៀង រួមទាំងបណ្តឹងសាទុក្ខភ្លាមៗ បញ្ហាអញ្ញត្រកម្ម/បឋម ដូចជា ការសម្រេចលើភាពអាចទទួលយកបាន ឬសូម្បីសំណើសុំបន្ថែមចំនួនទំព័រ ឬបន្ថែមពេលវេលាកំណត់។

## *ខ. ភាពយឺតយ៉ាវក្នុងសំណុំរឿងបច្ចុប្បន្ន*

16. ដើម្បីសម្រេចលើបញ្ហាទាន់ពេលវេលា ឬយឺតយ៉ាវ ជាការចាំបាច់ត្រូវពិចារណា៖

(១) នៅពេលណាដែលមូលដ្ឋាននៃភាពលម្អៀងលើកឡើងនេះ ត្រូវបានដឹងឮដោយភាគីដាក់សំណើ។

(២) នៅពេលណាដែលកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ដែលទទួលផលប៉ះពាល់ ដោយសារមូលដ្ឋាននៃភាពលម្អៀងលើកឡើងនេះ បានក្លាយជាជាក់លាក់ លែងជាសម្មតិកម្មទៀតនោះ និង

(៣) នៅចំណុចណាដែលអង្គជំនុំជម្រះតុលាការកំពូលបានទទួល ជាដំបូង នូវកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ដែលទទួលរងផលប៉ះពាល់ដោយមូលដ្ឋាននៃភាពលម្អៀងដែលលើកឡើង។

### *(១) មេធាវីការពារក្តីបានដឹងពីមូលដ្ឋានសម្រាប់ការប្តឹងជំទាស់ចិត្តរយៈពេលបីឆ្នាំ*

17. ដើម្បីកំណត់ឱ្យបានត្រឹមត្រូវថា នៅពេលណាដែលភាគីបានដឹងឮអំពីមូលដ្ឋាននៃសំណើសុំប្តឹងជំទាស់ចិត្ត ចាំបាច់ដែលត្រូវបកស្រាយដោយត្រឹមត្រូវពីមូលដ្ឋានទាំងអស់នេះ[13]។ មូលដ្ឋានដែលបានលើកឡើងក្នុងសំណើ គឺជាការអះអាងដែលថា ចៅក្រមដែលជំនុំជម្រះបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ មានភាពលម្អៀង ដោយសារតែពួកគាត់បានចូលរួមក្នុងសំណុំរឿងមុនកន្លងមក[14]។

[13] **ឯកសារលេខ ៨** សេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ចិត្តចៅក្រម យូ ប៊ុនឡេង ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៥-២១។

[14] ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៦, ៩។

មេធាវីការពារក្តីបានដឹងអំពីមូលដ្ឋាននេះ យ៉ាងហោចណាស់នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ នៅពេលដែលសាលដីកាក្នុងសំណុំរឿង ០០២/០១ ត្រូវបានប្រកាស។

18. តាមពិតទៅសហមេធាវីនាំមុខកត់សម្គាល់ ដោយពិនិត្យតាមបរិបទថា មេធាវីការពារក្តីមានមូលហេតុ ដែលអាចរំពឹងទុកពីបញ្ហានេះ តាំងពីមុនសាលដីកាមកម្ល៉េះ។ នៅក្នុងឆ្នាំ២០១៣ មានការផ្តួចផ្តើមការពិភាក្សាយ៉ាងលម្អិតទាក់ទងនឹងបញ្ហាថា តើត្រូវបង្កើតឱ្យមានក្រុមប្រឹក្សាជំនុំជម្រះថ្មីដែរឬទេ ដើម្បីជំនុំជម្រះសំណុំរឿង ០០២/០២[15]។ ជាលទ្ធផល នៅក្នុងខែធ្នូ ឆ្នាំ២០១៣ មានការសម្រេច

---

[15] នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើមោឃភាពដោយគ្មានព្យសនកម្ម ចំពោះការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយក្នុងសំណុំរឿង០០២ ហើយបញ្ជាក់ថា “ក្នុងករណីមានការបន្តការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អ.វ.ត.ក គប្បីបង្កើតឱ្យមានអង្គចៅក្រមជំនុំជម្រះមួយទៀត នៅក្នុងអង្គជំនុំជម្រះ ដើម្បីគាំទ្រដល់ការជំនុំជម្រះឱ្យបានទាន់ពេល ទៅលើផ្នែកដែលនៅសេសសល់នៃសំណុំរឿង០០២” ឯកសារ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ ៤៩, ៥០, ៥២។ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ នៅក្នុងបរិបទនៃសេចក្តីសម្រេចលើកទីពីររបស់ខ្លួន ចំពោះការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ “ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ស្វែងរកភ្លាមៗនូវលទ្ធភាពនៃការបង្កើតនៅក្នុងអង្គជំនុំជម្រះសាលាដំបូងនូវក្រុមប្រឹក្សាជំនុំជម្រះទីពីរ នៃចៅក្រមជាតិនិងចៅក្រមអន្តរជាតិ ដើម្បីស្តាប់ និងជំនុំជម្រះសំណុំរឿង០០២/០២”។ *សូមមើល* ឯកសារ **E284/4/7** សេចក្តីសង្ខេបនៃសំអាងហេតុសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង០០២ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ ១១ និងឯកសារ **E284/4/7** ដីកាសម្រេចបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ទំព័រ ២។ ការិយាល័យរដ្ឋបាលបានចេញអនុស្សរណៈចំនួនពីរ បន្ទាប់ពីដីកាសម្រេច ដោយបង្ហាញអំពីបញ្ហាប្រឈមផ្លូវច្បាប់ ដែលអាចកើតមានឡើងសម្រាប់ការបង្កើតក្រុមប្រឹក្សាបែបនេះ ព្រមទាំងលទ្ធភាពដែលអាចអនុវត្តបាន ឯកសារ **E284/7/1/1** អនុស្សរណៈអន្តរការិយាល័យ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣។ ឯកសារ **E284/7/1/2** អនុស្សរណៈអន្តរការិយាល័យ ដែលមានចំណងជើងថា “ដីកាសម្រេចទាក់ទងការបង្កើត ក្រុមប្រឹក្សាជំនុំជម្រះទីពីរ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣។ កិច្ចប្រជុំរៀបចំសវនាការត្រូវបានធ្វើឡើងនៅថ្ងៃទី១១ និងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ដែលភាគីនានាត្រូវបានអង្គជំនុំជម្រះសលាដំបូងអញ្ជើញចូលរួមពិភាក្សាអំពីនីត្យានុកូលភាព និងលទ្ធភាព នៃក្រុមប្រឹក្សាជំនុំជម្រះទីពីរ ព្រមទាំងសំណើសុំប្តឹងជំទាស់... ដែលអាចធ្វើឡើង ដោយសារតែចៅក្រមដដែល ធ្វើការជំនុំជម្រះទៅលើសំណុំរឿងទាំងពីរគឺ សំណុំរឿង០០២/០១ និងសំណុំរឿង០០២/០២។ *សូមមើល* ឯកសារ **E1/238.2** ប្រតិចារឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ទំព័រ ៨៨ បន្ទាត់ ១៩, ទំព័រ ៩៤ បន្ទាត់ ១០, និងទំព័រ៩៦ បន្ទាត់ ២១ ដល់ទំព័រ៩៧ បន្ទាត់ ៩។ តាមការអញ្ជើញរបស់អង្គជំនុំជម្រះសាលាដំបូង ភាគីទាំងអស់ត្រូវបានអញ្ជើញដោយច្បាស់លាស់ឱ្យផ្តល់មតិយោបល់ថាតើ នឹងមានការប្តឹងជំទាស់...ដែរឬយ៉ាងណា ដោយផ្អែកលើមូលដ្ឋានដែលថា ចៅក្រមតែមួយដែលសម្រេចសំណុំរឿង ០០២/០១ និងជំនុំជម្រះលើសំណុំរឿង ០០២/០២។

ថាមិនបង្កើតអង្គជំនុំជម្រះសាលាដំបូងថ្មីសម្រាប់សំណុំរឿង ០០២/០២ ទេ[16]។ ចៅក្រមដែលបានជំនុំជម្រះសំណុំរឿង ០០២/០១ នឹងត្រូវសម្រេចលើសំណុំរឿង ០០២/០២។

19. នៅក្នុងបរិបទនេះ បន្ទាប់ពីចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ មេធាវីការពារក្តីបានដាក់សំណើសុំប្តឹងជំទាស់លើកទីមួយរបស់ខ្លួន ទាក់ទងនឹងសំណុំរឿង០០២/០១។ សំណើនោះស្នើសុំ (ជំនួសឱ្យការផ្អាកកិច្ចដំណើរការនីតិវិធីរហូតដល់មានសាលដីកាស្ថាពរក្នុងសំណុំរឿង ០០២/០១) ប្តឹងជំទាស់ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង ដោយសារមូលហេតុមួយផ្នែកព្រោះតែតួនាទីរបស់ចៅក្រមទាំងអស់នោះ ក្នុងការសម្រេចលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១[17]។ (គួរឱ្យកត់សម្គាល់ សំណើនេះត្រូវបានដាក់នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ គឺរយៈពេលពីរសប្តាហ៍កន្លះ បន្ទាប់ពីចេញសាលក្រមអង្គជំនុំជម្រះសាលាដំបូង)។

20. នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ក្រុមប្រឹក្សាជំនុំជម្រះពិសេសនៃអង្គជំនុំជម្រះសាលាដំបូង ("ក្រុមប្រឹក្សាជំនុំជម្រះពិសេស") បានបដិសេធសំណើសុំប្តឹងជំទាស់[18]។ សំអាងហេតុត្រូវបានចេញនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់អង្គជំនុំជម្រះសាលាដំបូង")[19]។

---

[16] ឯកសារ **E301/4** អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរ នៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីជំនុំជម្រះលើការចោទប្រកាន់ ដែលមិនទាន់ត្រូវបានជំនុំជម្រះ នៅក្នុងសំណុំរឿង ០០២ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣។

[17] ឯកសារ **E314/1** សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញ ពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មី ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៧ -៤៨ ("ទោះជាយ៉ាងណាក៏ដោយ បើអង្គជំនុំជម្រះគ្រោងបដិសេធសំណើផ្អាកសវនាការ ដែលជាសំណើចម្បងនេះ មេធាវីការពារក្តីនឹងដាក់បណ្តឹងជំទាស់លើចៅក្រមរបស់អង្គជំនុំជម្រះទាំងអស់ (ដោយរួមបញ្ចូលទាំងចៅក្រមបម្រុង FENZ ផងដែរ ពីព្រោះគាត់បានចូលរួមជំនុំជម្រះជាច្រើនដងដែរ នៅក្នុងសវនាការសំណុំរឿង ០០២/០១ ហើយបានចូលរួមចេញសេចក្តីសម្រេចមួយចំនួនដែរ" ដើម្បីឱ្យសវនាការនៃសំណុំរឿង ០០២/០១ ដំណើរការទៅមុខ ប្រសិនបើត្រូវចាប់ផ្តើមភ្លាម ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាជំនុំជម្រះថ្មី ដែលមិនចេញសេចក្តីសម្រេច លើទំនួលខុសត្រូវព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ចំពោះអង្គហេតុដែលសន្មតថា ជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ និងសំណុំរឿងបន្តបន្ទាប់") *សូមមើល ផងដែរ* ឯកសារ **E314/8** បណ្តឹងប្តឹងជំទាស់ជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ន នៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០២/០២ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ១០។

[18] ឯកសារ **E314/12** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤។

[19] ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥។

ដោយសម្លេងភាគច្រើនលើសលប់ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានសម្រេចថា តួនាទីរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២/០១ មិនបានបង្កើតឲ្យមានភាពលម្អៀង ឬការយល់ឃើញពីភាពលម្អៀងដែលអាចនាំទៅដល់ការដិតចិត្តពីសំណុំរឿង ០០២/០២ ឡើយ[20]។

21. ទោះបីជាសេចក្តីសម្រេចនេះទាក់ទងជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង ដោយមិនទាក់ទងនឹងអង្គជំនុំជម្រះតុលាការកំពូលក្តី តែសំអាងហេតុក្នុងសេចក្តីសម្រេចនេះអាចអនុវត្តដោយផ្ទាល់បានចំពោះបញ្ហាថាតើចៅក្រមដដែលរបស់អង្គជំនុំជម្រះតុលាការកំពូល អាចជំនុំជម្រះបណ្តឹងសាទុក្ខណាមួយ នៅក្នុងសំណុំរឿង ០០២/០២ បានដែរឬទេ។ ជាលទ្ធផល ច្បាស់ណាស់ថា ដោយសារមានការប្រកាសសំអាងហេតុទាំងអស់នេះនៅក្នុងសេចក្តីសម្រេចលើបណ្តឹងដិតចិត្ត អង្គជំនុំជម្រះសាលាដំបូង មិនមានការកោះហៅក្រុមប្រឹក្សាជំនុំជម្រះថ្មីសម្រាប់អង្គជំនុំជម្រះតុលាការកំពូលដើម្បីជំនុំជម្រះបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០២ ឡើយ។ ចាប់តាំងពីពេលនោះមកមេធាវីការពារក្តីអាចប្រមើលមើលថា នៅក្នុងករណីដែលមានការផ្តន្ទាទោស លើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ បញ្ហានេះនឹងកើតមានឡើង។

22. ការផ្តន្ទាទោស ខៀវ សំផន នៅក្នុងដំណាក់កាលប្តឹងសាទុក្ខ បានធ្វើឡើងនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦។ ចាប់ពីពេលនោះមក មេធាវីការពារក្តីបានដឹងអំពីមូលដ្ឋាននៃបណ្តឹងដិតចិត្ត ដែលមេធាវីការពារក្តីព្យាយាមប្រើប្រាស់ទៅលើនាពេលនេះ គឺជាការចោទប្រកាន់ថា ចៅក្រមអង្គជំនុំជម្រះតុលាការកំពូលមានភាពលម្អៀង (ឬអាចយល់ឃើញថាលម្អៀង) ដោយសារតែពួកគាត់មានតួនាទីក្នុងការជំនុំជម្រះជនជាប់ចោទក្នុងសំណុំរឿង ០០២/០១។

---

[20] ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងដិតចិត្ត ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ១០៦ ("តាមរយៈការពិនិត្យទៅលើសាលក្រមសំណុំរឿង០០២/០១ ទាំងមូល រួមទាំងផ្នែកផ្សេងៗនៃសាលក្រម ដែលបណ្តឹងដិតចិត្តលើកឡើង ចៅក្រមអង្គជំនុំជម្រះសាលាដំបូងយល់ថា សំអាងហេតុរបស់ពួកគាត់ ត្រូវបានកម្រិតត្រឹមតែចំពោះសំណុំរឿង ០០២/០១ ប៉ុណ្ណោះ។ អង្គសង្កេតការណ៍មិនលម្អៀងនឹងទទួលស្គាល់ថា ចៅក្រមវិជ្ជាជីវៈមានលទ្ធភាពកាត់សេចក្តីលើរឿងក្តីជាប់ៗគ្នាប្រឆាំងនឹងជនជាប់ចោទដដែល ដូចការដែលគាត់អាចជំនុំជម្រះលើរឿងក្តីជាប់ៗគ្នា ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលជាប់ទាក់ទងគ្នានិងភស្តុតាងស្រដៀងគ្នាដែរ។ បណ្តឹងដិតចិត្តខកខានមិនបានបង្ហាញឲ្យឃើញថា អ្នកសង្កេតការណ៍មិនលម្អៀងអាចយល់ឃើញថា ចៅក្រមទាំងនោះអាចមិនមានលទ្ធភាព ប្រកាន់គំនិតឥតលម្អៀងចំពោះសំណុំរឿង ០០២/០១ នោះទេ។ ហេតុដូច្នេះសារណារបស់ នួន ជា និង ខៀវ សំផន ដែលថា សាលក្រមសំណុំរឿង ០០២/០១ មានបុរេនិច្ឆ័យទៅលើពិរុទ្ធភាពរបស់ពួកគេនៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានច្រានចោល") *សូមមើល ផងដែរ* កថាខណ្ឌ ៧៥ -៧៦, ៨០។

23. តាមពិតទៅ ការសន្និដ្ឋានថា មូលដ្ឋាននៃការចោទប្រកាន់អំពីភាពលម្អៀងត្រូវបានដឹងតាំងពីខែវិច្ឆិកា ឆ្នាំ២០១៦ ត្រូវបានគាំទ្រដោយទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសំណើសុំផ្ទាល់។ សំណើសុំបានជំទាស់ថា សេចក្តីសម្រេចលើបណ្តឹងជិតចិត្តអង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គង ហើយថា វិធីសាស្ត្រដ៏ត្រឹមត្រូវគឺត្រូវទទួលយកមតិជំទាស់របស់លោកចៅក្រម Downing[21]។ វិធីសាស្ត្រនោះត្រូវបានលើកឡើងដោយលោកចៅក្រម Downing ដូចតទៅ៖

> ...ទាក់ទងនឹងខៀវ សំផនវិញ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចកាលពេលមុន ទៅលើអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមដែលពាក់ព័ន្ធនឹងជនជាប់ចោទរូបនេះ គោលនយោបាយរបស់បក្សកុម្មុយនីស្តដែលត្រូវបានចោទប្រកាន់ ការចូលរួមពាក់ព័ន្ធទូទៅរបស់ ខៀវ សំផន នៅក្នុងគោលបំណងរួម និងនៅក្នុងបញ្ហាជាក់លាក់មួយចំនួន ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចជា ការបង្កើតសហករណ៍ និងការដ្ឋានធ្វើការងារ ភស្តុតាងដែលជាមូលដ្ឋានឧក្រិដ្ឋកម្ម ពាក់ព័ន្ធនឹងគោលនយោបាយនេះ និងធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដោយសារតែសំអាងហេតុទាំងនេះ ធ្វើឡើងហួសពីវិមតិសង្ស័យ ទាក់ទងនឹងជនជាប់ចោទដដែល នោះខ្ញុំយល់ឃើញថា សំអាងហេតុទាំងនោះគឺជាមូលហេតុ អាចឲ្យសន្និដ្ឋានបានថា អ្នកសង្កេតការណ៍មិនលម្អៀង ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ នឹងមានការយល់ឃើញដោយសមហេតុផលថា មានភាពលម្អៀងហើយ[22]។

24. ប្រសិនបើមេធាវីការពារក្តីអនុវត្តវិធីសាស្ត្រនេះពិតប្រាកដមែន ការចោទប្រកាន់អំពីភាពលម្អៀងបានកើតចេញពីការសម្រេចរបស់ចៅក្រម ទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០១។ មូលដ្ឋានដែលត្រូវបានចោទប្រកាន់នោះបានលេចចេញយ៉ាងច្បាស់ ពាក់ព័ន្ធនឹងចៅក្រមអង្គជំនុំជម្រះតុលាការកំពូល នៅពេលចេញសាលដីកានៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦។

25. មូលដ្ឋាននេះត្រូវបានមេធាវីការពារក្តីដឹង តាំងពីមុនពេលបញ្ចប់សវនាការសំណុំរឿង ០០២/០១ យ៉ាងយូរមកហើយ ហើយត្រូវបានបង្ហាញបន្ថែមទៀតតាមរយៈអង្គហេតុដែលថា មូលដ្ឋាននេះត្រូវ

[21] សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ ២៤-៥៥។ *សូមមើលជាពិសេស* កថាខណ្ឌ ២៦-២៨, ៥១។

[22] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៥០។

បានយោងយ៉ាងច្បាស់នៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីក្នុង សំណុំរឿង ០០២/០២ នៅក្នុងខែតុលា ឆ្នាំ២០១៧[23]។

26. ការយោងនៅក្នុងសំណើទៅលើ "មូលដ្ឋាន" ទីបី "រួមគ្នា" គឺជាការនាំឲ្យយល់ច្រឡំ។ "មូលដ្ឋាន" នេះពាក់ព័ន្ធនឹង "ភាពមិនប្រក្រតីផ្នែកនីតិវិធី ដែលបានកើតឡើងចាប់ពីពេលប្រកាសសាលក្រមអង្គជំនុំជម្រះសាលាដំបូង" ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៨។ តាមពិតទៅ បញ្ហាទាំងអស់នេះត្រឹមតែជា "ភស្តុតាងគាំទ្រ" ប៉ុណ្ណោះ ពាក់ព័ន្ធទៅនឹងមូលដ្ឋានដែលបានដឹងរួចទៅហើយ។ មេធាវីការពារក្តីខ្លួនឯងក៏បានលើកទឡ្ហីករណ៍ថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ "ពង្រឹង" ការសន្និដ្ឋានរបស់ខ្លួនដែលថា ចៅក្រមមានភាពលម្អៀង ដោយសារតែពួកគាត់បានចូលរួមនៅក្នុងសំណុំរឿង ០០២/០១។ នៅក្នុងបណ្តាសេចក្តីសម្រេចទាំងនោះ មិនមានអ្វីដែលរារាំងដល់មេធាវីការពារក្តី ដូចដែលមេធាវីការពារក្តីបានលើកឡើងថា បង្កើតបានជាកំហុស ដោយមិនបានពន្យល់ពីមូលហេតុអ្វី ទើបកំហុសឆ្គងទាំងនោះអាចចាត់ទុកថាជាភាពលម្អៀង ហើយបង្ហាញមូលដ្ឋានមួយផ្សេងទៀត ដែលអាចនិយាយបានថាកើតចេញពីការចូលរួមរបស់ចៅក្រមនៅក្នុងសំណុំរឿង ០០២/០១ ឡើយ។ តាមពិតទៅ ប្រសិនបើមូលដ្ឋានមួយផ្សេងបានកើតឡើង ដោយសារតែសេចក្តីសម្រេចទាំងនោះ នៅតែមានភាពមិនច្បាស់លាស់ថាហេតុអ្វីទើបចៅក្រម Harding Clark មិនត្រូវបានបញ្ចូលទៅក្នុងសំណើ។ គាត់ស្ថិតក្នុងចំណោមចៅក្រមដែលចេញសេចក្តីសម្រេចថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ជាសេចក្តីសម្រេចដែលមេធាវីការពារក្តីបានជំទាស់នៅត្រង់កថាខណ្ឌ១១៣ នៃសំណើ[24]។

27. សម្រាប់សំអាងហេតុទាំងអស់នេះ សហមេធាវីនាំមុខលើកឡើងថា មេធាវីការពារក្តីបានដឹងអំពីមូលដ្ឋានដែលស្ថិតនៅក្នុងសំណើ តាំងពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦។ ដូច្នេះ អ្វីដែលនៅសល់គឺការ

---

[23] ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ និងបានកែសម្រួលនៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ ៦៥៦។

[24] ឯកសារ **E463/1/5** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេចលេខ E463/1/3 លើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ទំព័រដើម។ *សូមមើល* ឧបសម្ព័ន្ធ ១៖ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក ដែលមានចំណងជើងថា "ការតែងតាំងចៅក្រមថ្មីនៃ អ.វ.ត.ក" ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការតែងតាំងចៅក្រម Harding Clark ជាចៅក្រមអង្គជំនុំជម្រះតុលាការកំពូល។

សម្រេចនៅចំណុចណាដែលបញ្ហានេះអាចកើត និងមានភាពចាំបាច់ក្នុងការលើកឡើង ទៅតាមការដឹង ហើយនឹងអត្ថិភាពនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសារទុក្ខ។

*(២) មេធាវីការពារក្តីបានដឹងអំពីចេតនាខ្លួនក្នុងការប្តឹងសារទុក្ខតាំងពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨*

28. សាលក្រមសង្ខេបត្រូវបានអង្គជំនុំជម្រះសាលាដំបូងប្រកាស នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលក្នុងនោះ សេចក្តីសម្រេចសំខាន់ៗត្រូវបានប្រកាស រួមទាំងការសម្រេចដែលបានជំទាស់ អំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ ខៀវ សំផន។ មេធាវីការពារក្តីបានដឹងយ៉ាងច្បាស់ថា ខ្លួននឹងប្តឹងសាទុក្ខប្រឆាំងនឹងការផ្តន្ទាទោស ខៀវ សំផន។ សេចក្តីប្រកាសព័ត៌មានអំពីការប្តឹងសាទុក្ខនេះត្រូវបានផ្តល់ទៅសារព័ត៌មាន[25]។ ចាប់ពីពេលនោះមក បញ្ហានៃភាពលម្អៀងដែលរងការចោទប្រកាន់ ចំពោះចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ដែលជំនុំជម្រះលើសំណុំរឿង ០០២/០១ លែងជាការសន្មតទៀតហើយ។ មេធាវីការពារក្តីបានដឹងថា ខ្លួននឹងប្តឹងសាទុក្ខ។ មេធាវីការពារក្តីបានដឹង ហើយបានដឹងយ៉ាងហោចណាស់ចាប់ពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ថា ចៅក្រមដដែលជំនុំជម្រះបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ នឹងជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់ខ្លួន។

29. មិនមានភាពពាក់ព័ន្ធអ្វីឡើយដែលថា នៅពេលនេះមេធាវីការពារក្តី មិនទាន់បានដឹងអំពីសំអាងហេតុពេញលេញ ដែលខ្លួនត្រូវប្តឹងសាទុក្ខនោះ (ដោយសារតែសំអាងហេតុពេញលេញ សម្រាប់សាលក្រមត្រូវបានប្រកាសនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩)។ សំណើបានបង្ហាញច្បាស់ថា មេធាវីការពារក្តីបានពិចារណារួចហើយថា ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ដែលចូលរួមក្នុងសំណុំរឿង ០០២/០១ មានភាពលម្អៀងចំពោះបញ្ហាទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន។ បណ្តឹងសាទុក្ខណាទាក់ទងនឹងការផ្តន្ទាទោស ខៀវ សំផន នឹងត្រូវទទួលរងប៉ះពាល់ដោយសារភាពលម្អៀងនេះ។

30. ប្រសិនបើមេធាវីការពារក្តី ព្រួយបារម្ភពិតប្រាកដអំពីភាពលម្អៀងដែលអាចកើតមាននៅក្នុងអង្គជំនុំជម្រះតុលាការកំពូល មេធាវីការពារក្តីមិនត្រូវប្រឹងប្រែងប្តឹងដិតចិត្តនៅពេលនេះទេ គឺគួរធ្វើនៅពេលភ្លាមៗបន្ទាប់ពីខ្លួនច្បាស់ប្រាកដថា មេធាវីការពារក្តីចាំបាច់ត្រូវដាក់ជូនអង្គជំនុំជម្រះនូវបណ្តឹងសាទុក្ខនោះ។ តាមពិតទៅ ជំនួសឲ្យការព្យាយាមប្តឹងដិតចិត្តចៅក្រមភ្លាមៗ ដើម្បីរារាំងកុំឲ្យភាពលម្អៀងដែលបានចោទប្រកាន់ បង្កផលប៉ះពាល់ដល់កិច្ចដំណើរការនិតិវិធី បណ្តឹងសាទុក្ខសំណុំ

[25] *សូមមើលជាទូទៅ* ឧបសម្ព័ន្ធ ២៖ អត្ថបទសារព័ត៌មាន។

រឿង ០០២/០២ នឹងរារាំងកុំឲ្យមានការពន្យារពេលដល់កិច្ចដំណើរការនីតិវិធីនោះ មេធាវីការពារក្តីបែរជាចូលរួមយ៉ាងផុសផុលនៅក្នុងបណ្តឹងនានានៅចំពោះមុខចៅក្រមដែលត្រូវបានប្តឹងនាពេលនេះ ដូចដែលនឹងរៀបរាប់នៅផ្នែកខាងក្រោម។

*(៣) កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ បានចាប់ផ្តើមនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨*

31. ទោះបីជាមេធាវីការពារក្តីអាច និងគួរតែដាក់សំណើសុំប្តឹងជិតចិត្ត ភ្លាមៗបន្ទាប់ពីបានដឹងថា ខ្លួននឹងប្តឹងសាទុក្ខក្តី ក៏វិធាន ៣៤(៤) នៃវិធានផ្ទៃក្នុងបានចែងយ៉ាងច្បាស់ថា សំណើបែបនេះអាចទទួលយកបានតែក្នុងករណីដែលសំណើនេះត្រូវបានដាក់ភ្លាមៗ នៅពេលដែលកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល បានចាប់ផ្តើមឡើង។ កិច្ចដំណើរការនីតិវិធីបានចាប់ផ្តើមនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅពេលដែល "បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨" ("បណ្តឹងសាទុក្ខភ្លាមៗ") ត្រូវបានដាក់[26]។

32. ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចជាចុងក្រោយថា បណ្តឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្តី មិនអាចទទួលយកបានក្តី[27] តែអង្គជំនុំជម្រះតុលាការកំពូលបានទទួលយកសំណើនោះ ដែលតម្រូវឲ្យមាន (ហើយបានទទួល) ការសម្រេចតាមផ្លូវតុលាការរបស់ខ្លួន ហើយដែលជាប់ទាក់ទងជាមូលដ្ឋានជាមួយនឹងពេលវេលា និងនីតិវិធី ដែលពាក់ព័ន្ធនឹងការផ្តន្ទាទោស ខៀវ សំផន។ និយាយម្យ៉ាងទៀត បញ្ហាដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខភ្លាមៗ គឺជាបញ្ហាដែលទទួលផលប៉ះពាល់ ដោយសារមូលដ្ឋានដែលត្រូវលើកឡើងនាពេលនេះ ប្រសិនបើមូលដ្ឋាននោះមានអង្គសេចក្តី។ តាមពិតទៅ មេធាវីការពារក្តីនាពេលនេះព្យាយាមលើកទឡ្ហីករណ៍ថា សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់អង្គជំនុំជម្រះតុលាការកំពូលមានភាពលម្អៀងទៅវិញទេ[28]។

33. ទោះជាបែបនេះក្តី មេធាវីការពារក្តីនៅតែផ្តល់ទំនុកចិត្តចំពោះពួកគាត់ ដោយដាក់បណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួន ដល់ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ដែលខ្លួនកំពុងប្តឹងជិតចិត្តនាពេលនេះ។

---

[26] ឯកសារ **E463** បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។

[27] ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសម្រេចសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ កថាខណ្ឌ ១៧។

[28] សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ ១១១។

នៅបួនខែក្រោយមក គឺនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ជាថ្មីម្តងទៀត មេធាវីការពារក្តីបានដាក់ជូនអង្គជំនុំជម្រះតុលាការកំពូលនូវសំណើមួយដែលក្នុងសំណើនេះ មេធាវីការពារក្តីបានស្នើចៅក្រមដដែល (ហើយជាចៅក្រមដែលនាពេលនេះ ត្រូវបានគេចោទប្រកាន់ថាលម្អៀង) ឲ្យធ្វើមោឃភាពសេចក្តីសម្រេចរបស់ចៅក្រមលើបណ្តឹងសាទុក្ខភ្លាមៗ។

34. ជាបញ្ហាបន្ថែមទៀតនោះ កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខសំខាន់ (មិនមែនភ្លាមៗ) ទាក់ទងនឹងសំអាងហេតុសម្រាប់សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ បានចាប់ផ្តើមនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ នៅពេលដែលសហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[29] ហើយមេធាវីការពារក្តីបានដាក់ចម្លើយតបរបស់ខ្លួននៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះដដែល នៃអង្គជំនុំជម្រះតុលាការកំពូល[30]។ បើតាមហេតុផលរបស់មេធាវីការពារក្តី បណ្តឹងសាទុក្ខនេះពិតជាទទួលផលប៉ះពាល់ ដោយសារការចោទប្រកាន់របស់ខ្លួនពីភាពលម្អៀងដែរ ព្រោះបណ្តឹងសាទុក្ខនេះ ទាក់ទងជាមូលដ្ឋានជាមួយនឹងបញ្ហានៃការកំណត់ប្រភេទបទល្មើសនៃអំពើដែល ខៀវ សំផន ត្រូវបានផ្តន្ទាទោស។ តាមពិតទៅ សំណើហាក់ដូចជាស្នើសុំប្តឹងជំទាស់ចិត្តទាំងស្រុងចំពោះចៅក្រមទាំងប្រាំមួយរូប ចេញពីកិច្ចដំណើរការនីតិវិធីទាំងអស់ក្នុងសំណុំរឿង ០២/០២ រួមទាំងការសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

35. ហេតុដូច្នេះ សហមេធាវីនាំមុខសូមលើកឡើងថា នីតិវិធីបណ្តឹងសាទុក្ខបានចាប់ផ្តើមជាលើកដំបូងនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។ នីតិវិធីបណ្តឹងសាទុក្ខបន្តទៀតបានចាប់ផ្តើមដោយមេធាវីការពារក្តីផ្ទាល់ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ និងដោយសហព្រះរាជអាជ្ញានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩។

*(៤) ហេតុដូច្នេះសំណើត្រូវបានដាក់យឺតពេលខ្លាំង*

36. ដោយផ្អែកទៅលើការលើកឡើងនៅផ្នែកខាងលើ ច្បាស់ណាស់ថា មេធាវីការពារក្តី បានដឹងអំពីមូលដ្ឋាននៃភាពលម្អៀងដែលបានចោទប្រកាន់ យ៉ាងហោចណាស់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ

---

[29] ឯកសារ **E465/2/1** សេចក្តីជូនដំណឹងរបស់ សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩។

[30] ឯកសារ **F50/1** ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (សំណុំរឿង ០០២/០២) ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។

២០១៦។ មេធាវីការពារក្ដីមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំសារណារបស់ខ្លួន។ សារណានោះគួរតែដាក់ភ្លាមៗ បន្ទាប់ពីមេធាវីការពារក្ដីបានដឹងថា ខ្លួននឹងប្ដឹងសារទុក្ខទៅលើការផ្ដន្ទាទោស ខៀវ សំផន នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ នេះជាការតម្រូវដែលមិនអាចប្រកែកបានក្នុងការដាក់សំណើមិនឲ្យយឺតជាង ពេលចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ ជាដំណាក់កាលមួយដែលមេធាវីការពារក្ដីខ្លួនឯង បានចាប់ផ្ដើមនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។

37. ប្រសិនបើមេធាវីការពារក្ដី ពិតជាបារម្ភអំពីភាពលម្អៀងនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់នេះមែន មេធាវីការពារក្ដីពិតជាត្រូវលើកបញ្ហានេះ នៅពេលវេលាភ្លាមៗនោះមិនខាន។ ប៉ុន្តែ ជាជំនួសទៅវិញ មេធាវីការពារក្ដីបានដាក់បណ្ដឹងសាទុក្ខភ្លាមៗ[31] សំណើសុំមោឃភាពផ្នែកលើសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ[32] ការជូនដំណឹងអំពីបណ្ដឹងសាទុក្ខ[33] សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ[34] សារណាលើសច្ចធារណ៍នៃនិរទោស បន្ទាប់ពីមរណភាពរបស់ នួន ជា[35] សារណាចម្លើយតប[36] និងសំណើសុំដាក់ភស្តុតាងបន្ថែម[37] ដែលឯកសារទាំងអស់នេះត្រូវដាក់នៅចំពោះមុខចៅក្រមដែលនាពេលនេះមេធាវីការពារក្ដីបានអះអាងថាគួរត្រូវបានដកចេញ ដោយសារតែមូលហេតុដែលបានដឹង តាំងពីយូរយារណាស់មកហើយ។

---

[31] ឯកសារ **E463/1** Appel urgent de KHIEU Samphân contre le jugement pronouncé le 16 novembre 2018, ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។

[32] ឯកសារ **E463/1/4** សំណើរបស់លោក ខៀវ សំផន សុំធ្វើមោឃភាពសេចក្ដីសម្រេច E463/1/3 លើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

[33] ឯកសារ **E465/4/1** Déclaration d'appel de KHIEU Samphân (002/02) ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

[34] ឯកសារ **F39/1.1** សំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលានិងចំនួនទំព័រ របស់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩។ ឯកសារ **F44** សំណើរបស់លោក ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញលើ សេចក្ដីសម្រេចស្ដីពីការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ សម្រាប់ដាក់សេចក្ដីជូនដំណឹង អំពីបណ្ដឹងសាទុក្ខ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៩។ ឯកសារ **F45** សំណើរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ នៃសារណាបណ្ដឹងសាទុក្ខ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩។

[35] ឯកសារ **F46/2/4/1** ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងសច្ចធារណ៍និរទោស នៅដំណាក់កាលបណ្ដឹងសាទុក្ខ (ឯកសារ F46/2/4), ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩។

[36] ឯកសារ **F50/1** ចម្លើយតបរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (សំណុំរឿង ០០២/០២) ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។

[37] ឯកសារ **F51** សំណើរបស់លោក ខៀវ សំផន សុំឲ្យទទួលយកភស្តុតាងបន្ថែម ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩។

38. ជាការពិតទៅ មេធាវីការពារក្ដីព្យាយាមដោយមានៈ ដើម្បីទទួលបានផលប្រយោជន៍ពីការពន្យារពេលផ្ទាល់របស់ខ្លួន ដោយលើកទឡ្ហីករណ៍ថា សេចក្ដីសម្រេចដែលធ្វើឡើងជាការឆ្លើយតបចំពោះសារណាផ្ទាល់របស់ខ្លួន "ពង្រឹង" ដល់ការចោទប្រកាន់អំពីភាពលម្អៀង។ ប្រសិនបើសំណើសុំប្ដឹងជំទាស់ ត្រូវបានធ្វើឡើងនៅពេលវេលាសមស្រប បញ្ហានឹងត្រូវបានដោះស្រាយ មុនពេលដែលកិច្ចដំណើរការនីតិវិធីទាំងអស់នេះ បានចាប់ផ្ដើមអនុវត្ត។ ដូចដែលក្រុមប្រឹក្សាជំនុំជម្រះពិសេស បានសម្រេចនៅក្នុងសេចក្ដីសម្រេចលើបណ្ដឹងជំទាស់អង្គជំនុំជម្រះសាលាដំបូង "ការពន្យារពេលដ៏អាក្រក់បំផុត កើតមានឡើងនៅពេលដែលភាគីមួយដឹងរួចហើយអំពីអង្គហេតុ ដែលអះអាងថាបង្ហាញឲ្យឃើញពីការលេចចេញនូវភាពលម្អៀង ប៉ុន្តែភាគីនោះរង់ចាំរហូតដល់ក្រោយពីមានការចេញសេចក្ដីសម្រេចអវិជ្ជមាន ទើបលើកឡើងនូវបញ្ហានៃការប្ដឹងជំទាស់"[38]។ វិធីសាស្ត្រដែលមេធាវីការពារក្ដីបានអនុវត្ត នឹងអនុញ្ញាតឲ្យភាគីនានាអាចកំណត់បានពីភាពលម្អៀងដែលបានចោទប្រកាន់ ប៉ុន្តែ ជំនួសឲ្យការដាក់សំណើសុំប្ដឹងជំទាស់ បែរជាដាក់សារណាជូនចៅក្រមដែលកំពុងមានបញ្ហានូវសារណាទាំងឡាយដែលជាភស្តុតាងនៃភាពលម្អៀងដែលមានអត្ថិភាពពីមុន។ ច្បាស់ណាស់ថា វិធីសាស្ត្រនេះបំពានទាំងទៅលើពាក្យពេចន៍ និងទៅលើស្មារតីនៃវិធាន ៣៤ នៃវិធានផ្ទៃក្នុង។ វិធីសាស្ត្រនេះមិនគួរអនុញ្ញាតឲ្យមានទេ។

## (២) ផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យច្រានចោលសំណើ

39. នៅពេលពិចារណាទៅលើសំណើដែលមានលក្ខណៈដូចគ្នាផ្នែកទម្រង់ដែលបានដាក់កាលពីឆ្នាំ ២០១៤ ទាក់ទងនឹងអង្គជំនុំជម្រះសាលាដំបូង ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានបង្ហាញពី "មន្ទិលសង្ស័យ" អំពីការពន្យារពេលយ៉ាងជាក់ច្បាស់ក្នុងការលើកឡើងនូវសំណើ ប៉ុន្តែ ក្រុមប្រឹក្សាបានសម្រេចថា "ជារួម ការទទួលយកបណ្ដឹងជំទាស់ទាំងអស់ និងឆ្លើយតបចំពោះសំណើនានា ដែលបានលើកឡើងនោះ គឺជាផលប្រយោជន៍នៃយុត្តិធម៌"[39]។ ហេតុដូច្នេះ អង្គជំនុំជម្រះហាក់ដូចជាមានឆន្ទានុសិទ្ធិក្នុងការពិចារណា និងសម្រេចទៅលើអង្គសេចក្ដីនៃសំណើសុំប្ដឹងជំទាស់ បើទោះបីជាសំណើនោះហាក់ដូចជាមិនអាចទទួលយកបានក្ដី តាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង នៅពេលដែលការទទួលយកនោះ គឺដើម្បីប្រយោជន៍យុត្តិធម៌។

---

[38] ឯកសារ E314/12/1 សំអាងហេតុចំពោះសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៣២។

[39] ឯកសារ E314/12/1 សំអាងហេតុចំពោះសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៣២។

40. សហមេធាវីនាំមុខសង្កត់ធ្ងន់ថា កាលៈទេសៈបច្ចុប្បន្នគឺខុសគ្នាឆ្ងាយណាស់ពីកាលៈទេសៈដែលបានកើតឡើងនៅក្នុងឆ្នាំ២០១៤។ ក្នុងកាលៈទេសៈនេះ ផលប្រយោជន៍យុត្តិធម៌ពិតជាតម្រូវឱ្យបដិសេធយ៉ាងជាក់ច្បាស់ចំពោះសំណើនេះថាមិនអាចទទួលយកបាន។ ការបដិសេធនេះគឺដោយសារមូលហេតុជាច្រើន៖

### *ក. ការពន្យារពេល និងការប្រព្រឹត្តិរបស់មេធាវីការពារក្តី ខុសប្លែកខ្លាំងពីធម្មតា*

41. ជាដំបូង ឥរិយាបថរបស់មេធាវីការពារក្តី មានបញ្ហាខ្លាំងនៅក្នុងស្ថានភាពបច្ចុប្បន្ន។ ឥរិយាបថគួរឱ្យកត់សម្គាល់គ្រង់ ការពន្យារពេលយ៉ាងយូរ ដោយមានយុត្តិកម្មទន់ខ្សោយ ហើយបានអនុវត្តដំណើរការវិជ្ជមានមួយចំនួន ដើម្បីពាក់ព័ន្ធជាមួយចៅក្រមតែមួយ ដែលនាពេលនេះត្រូវបានប្តឹងតាមរយៈសំណើនេះ។

42. នៅក្នុងសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត អង្គជំនុំជម្រះសាលាដំបូង ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានពិចារណាថា យ៉ាងហោចណាស់ ក៏អាចមានការពិភាក្សាដែរថា មូលដ្ឋានមួយចំនួនត្រូវបានបង្ហាញពេញលេញដល់មេធាវីការពារក្តី នៅពេលចេញសាលក្រមអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ប៉ុណ្ណោះ។ សំណើសុំប្តឹងជំទាស់ចិត្តទីមួយ ត្រូវបានដាក់នៅរយៈពេល ១១ ថ្ងៃក្រោយ។ ក្នុងស្ថានភាពបច្ចុប្បន្ននេះ មានការពន្យារពេលសឹងតែមួយឆ្នាំពេញ ចាប់តាំងពីពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។

43. សំណើផ្ទាល់មិនបានពន្យល់អំពីមូលហេតុនៃការពន្យារពេលនេះទេ។ សំណើមិនបានពន្យល់សូម្បីតែការពន្យារពេល ដោយសារតែកាលបរិច្ឆេទ ដែលសំណើបានលើកឡើង (ដោយខុសឆ្គង) ថាជាពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ គឺថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។ មានភាពមិនច្បាស់លាស់ថាតើហេតុអ្វីទើបសំណើសុំដែលមាន ៣០ ទំព័រ មូលដ្ឋានដែលត្រូវបានដឹងរាប់ឆ្នាំ និងទឡ្ហីករណ៍ដែលភាគច្រើនលើសលប់ គឺជាទឡ្ហីករណ៍ចម្លងដែលធ្វើឡើងចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូង កាលពីឆ្នាំ២០១៤ បែរជាត្រូវការពេលវេលារាប់ខែដើម្បីបង្កើតឡើង បើទោះបីជាមេធាវីការពារក្តី ប្រឈមមុខជាមួយបញ្ហាធនធានមានកំណត់ក្តី។

44. បញ្ហាកាន់តែអាក្រក់ឡើងដោយសារថា មេធាវីការពារក្តីបានទទួលការជូនដំណឹងយ៉ាងច្បាស់ ចាប់តាំងពីសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ អំពីតម្រូវការក្នុងការដាក់សំណើសុំប្តឹងជំទាស់ចិត្តឱ្យបានទាន់ពេលវេលា។

45. ដោយមិនអនុវត្តបែបនេះ មេធាវីការពារក្តីបែរជាដាក់សំណើម្តងហើយម្តងទៀតនៅចំពោះមុខថៅក្រមដដែល ដែលនាពេលនេះ ពួកគេព្យាយាមប្តឹងជំទាស់លើភាពមិនលម្អៀងទៅវិញ។ មេធាវីការពារក្តីបានយោងយ៉ាងច្បាស់ទៅលើអង្គហេតុដែលសំណើសុំប្តឹងជិតចិត្តបានគិតបម្រុងទុក[40] ដោយមេធាវីការពារក្តី ក្នុងករណីមួយនោះ ហាក់ដូចជាលើកឡើងថា ការធ្វើបែបនេះបានកាត់បន្ថយព្យសនកម្ម ដោយសារតែការពន្យារពេល[41]។ ការអះអាងបែបនេះមិនគួរឲ្យជឿជាក់នោះទេ។ មិនមានភាគីណាមួយ ឬគណៈកម្មាធិការរដ្ឋបាលតុលាការណាមួយ អាចបំពេញកិច្ច ផ្អែកលើការយោងបែបប៉ានស្មាន អំពីលទ្ធភាពនៃសំណើសុំប្តឹងជិតចិត្តនាពេលអនាគត។ តាមពិតទៅ ការណ៍ដែលថា មានការលើកឡើងនូវការយោងបែបនេះ គឺគ្រាន់តែជាភស្តុតាងបន្ថែមនៃការពន្យារពេលប៉ុណ្ណោះ ដោយការយោងនេះបង្ហាញដោយមិនអាចប្រកែកបាន អំពីការដឹងអំពីមូលដ្ឋាន តាំងពីយូរមកហើយរបស់មេធាវីការពារក្តី ហើយដែលបច្ចុប្បន្ននេះត្រូវបានលើកឡើងដោយយឺតយ៉ាវ។

## *ខ. ការពិចារណាទៅលើសំណើ បើទោះបីជាមានការពន្យារពេល នឹងបង្កព្យសនកម្មចំពោះសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី*

46. ការពន្យារពេលក្នុងការដាក់សំណើ បង្កជាបញ្ហា មិនត្រឹមតែជាបញ្ហានៃគោលការណ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសក្តានុពល ក្នុងការបង្កទៅជាព្យសនកម្មពិតប្រាកដចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង កំណត់ថា សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានគិតគូរពិចារណានៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក។

47. សុវត្ថិភាពគតិយុត្តិគឺជាគោលការណ៍សំខាន់ជាមូលដ្ឋាននៃកិច្ចដំណើរការនីតិវិធី អ.វ.ត.ក ដែលដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្រើប្រាស់[42]។ ជាលទ្ធផល នៅពេលដែលការជំទាស់ផ្នែកនីតិវិធី មិនត្រូវបានដាក់ទៅតាមពេលវេលាតម្រូវ ភាគីដទៃទៀតមានសិទ្ធិក្នុងការសន្និដ្ឋានថា មិនមានការលើក

---

[40] ឯកសារ **F39/1.1** សំណើរបស់លោក ខៀវ សំផន សុំពន្យាពេលនិងបន្ថែមចំនួនទំព័រ នៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ៣៥។

[41] *សូមមើល* ជាពិសេសការអះអាងថា ការត្រៀមរៀបចំអាចធ្វើឡើងរួចរាល់ សម្រាប់ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះពិសេស នៅក្នុងឯកសារ **E465/1/4** ការជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (សំណុំរឿង ០០២/០២) ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ កថាខណ្ឌ ១៤។

[42] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

ឡើងពីញត្តិបែបនេះទេ។ គោលការណ៍ដែលពាក់ព័ន្ធជិតស្និទ្ធគឺថា កិច្ចដំណើរការនីតិវិធីចាំបាច់ត្រូវតែដោះស្រាយឱ្យបានឆាប់រហ័ស[43]។

48. ប្រសិនបើបញ្ហានេះត្រូវបានប្តឹងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះតុលាការកំពូលនឹងមានពេលវេលាជាច្រើន ដើម្បីចេញសេចក្តីសម្រេច នៅមុនពេលដែលអង្គជំនុំជម្រះតុលាការកំពូល និងបុគ្គលិកអង្គជំនុំជម្រះបំពេញការងារសំខាន់ៗលើបណ្តឹងសាទុក្ខ។ ដូចដែលបានឃើញនាពេលនេះ ក្រុមប្រឹក្សាជំនុំជម្រះរបស់អង្គជំនុំជម្រះតុលាការកំពូល មិនត្រឹមតែបានដោះស្រាយបញ្ហាសំខាន់ៗមួយចំនួន (មិនត្រឹមតែសាលដីកាលើបណ្តឹងសាទុក្ខភ្លាមៗ និងសំណើសុំមោឃភាព របស់ ខៀវ សំផន ព្រមទាំងសេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំង នួន ជា) ប៉ុណ្ណោះទេ ប៉ុន្តែការដាក់បណ្តឹងសាទុក្ខត្រូវបានបញ្ចប់ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាចំពោះសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

49. ការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះពិសេស ដើម្បីសម្រេចលើសំណើ នឹងតម្រូវឱ្យមានពេលវេលាបន្ថែម ពីបុគ្គលិកអង្គជំនុំជម្រះតុលាការកំពូល និងចៅក្រម Harding Clark ដូច្នេះហើយនឹងពន្យារពេលដល់ការងារលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងបញ្ហាដទៃផ្សេងទៀត ដែលនៅរង់ចាំចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល។ ក្នុងករណីដែលសំណើត្រូវបានសម្រេចតាម ចាំបាច់ត្រូវស្វែងរកចៅក្រមថ្មី ហើយការងារចម្បងៗទាំងអស់លើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានឹងត្រូវចាប់ ផ្តើមឡើងវិញ។

50. ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានប្រយោជន៍ខ្លាំងពីការជៀសវាងការពន្យារពេលបែបនេះ។ ក្នុងករណីណាក៏ដោយ នៅពេលដែលជនរងគ្រោះរង់ចាំការសម្រេចតាមផ្លូវតុលាការជាស្ថាពរ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងពួកគាត់ ពួកគាត់នឹងទទួលបានផលប្រយោជន៍ នៅពេលដែលការសម្រេចត្រូវបានធ្វើឡើងក្នុងពេលវេលាសមស្របមួយ[44]។ ផលប្រយោជន៍នេះកាន់តែខ្លាំង នៅក្នុងសំណុំ

---

[43] មាត្រា ៣៣*ថ្មី* និងមាត្រា ៣៧*ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ។ ឯកសារ **F49** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់ សារណាបណ្តឹងសាទុក្ខ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ កថាខណ្ឌ១៩។

[44] តុលាការព្រហ្មទណ្ឌអន្តរជាតិ *រដ្ឋអាជ្ញា តទល់នឹង Dominic Ongwen* សាលដីកាបណ្តឹងសាទុក្ខរបស់លោក Dominic Ongwen ប្រឆាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង IX "សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ដែលចោទប្រកាន់អំពីកំហុសឆ្គងនៅក្នុងសេចក្តីសម្រេចគាំទ្រ" ICC-02/04-01/15-1562 ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ កថាខណ្ឌ ១៣៦

រឿងបច្ចុប្បន្ន ពីព្រោះតែវ័យចាស់ជរារបស់ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើន។ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានស្លាប់នៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធី។ អ្នកដែលបន្តតាមដានកិច្ចដំណើរការនីតិវិធីអន្ទះសារចង់បានសេចក្តីសម្រេចក្នុងពេលវេលាសមស្រប។ ហេតុដូច្នេះ ការពន្យារពេលបន្ថែមទៀតសម្រាប់ការសន្និដ្ឋានបញ្ចប់ស្ថាពរទៅលើសំណុំរឿងនេះ ចាំបាច់ត្រូវតែកាត់បន្ថយឱ្យនៅតិចបំផុត ហើយវិធាននីតិវិធីដែលរៀបចំឡើងដើម្បីធានាពីភាពឆាប់រហ័ស ត្រូវតែអនុវត្តឱ្យបានខ្លាំងក្លា។

## *គ. សំណើមិនបានលើកឡើងអំពីបញ្ហាថ្មី ឬបញ្ហាធ្ងន់ធ្ងរឡើយ*

51. សំណើសុំប្តឹងជំទាស់ឆ្នាំ២០១៤ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះសាលាដំបូង បានបង្ហាញជាលើកដំបូងថា បញ្ហាជាក់លាក់មួយនេះបានកើតឡើងនៅចំពោះ អ.វ.ត.ក ឬតាមពិតទៅតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងដែរ។ បញ្ហាប្រហែលគ្នាមួយត្រូវបានលើកឡើងពាក់ព័ន្ធនឹងការចូលរួមរបស់ក្រុមប្រឹក្សាជំនុំជម្រះតែមួយ នៅក្នុងសំណុំរឿងពាក់ព័ន្ធគ្នាជាច្រើនប្រឆាំងនឹងជនជាប់ចោទផ្សេងៗគ្នា។ ទោះជាយ៉ាងណាក្តី ការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ បានបង្កើតជាសេណារីយ៉ូថ្មីមួយទាំងស្រុង ដែលក្នុងនោះ ជនជាប់ចោទដដែលគឺជាចុងចម្លើយនៃសំណុំរឿងចំនួនពីរផ្សេងពីគ្នា។

52. ដោយសារតែសារៈសំខាន់នៃបញ្ហា និងការដែលថា មិនមានយុត្តិសាស្ត្រណាមួយពីមុនមក នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ការសម្រេចទៅលើបញ្ហានេះមានប្រយោជន៍ច្បាស់ណាស់។ ការធ្វើបែបនេះបណ្តាលឱ្យមានសុវត្ថិភាពគតិយុត្តិ ដោយសារតែ ប្រសិនបើបញ្ហានេះមិនត្រូវបានសម្រេចនៅដំណាក់កាលនេះទេ បញ្ហានេះអាចត្រូវបានលើកឡើង តាមវិធីផ្សេងមួយទៀត នៅពេលក្រោយ ហើយអាចបង្កហានិភ័យដែលថា កិច្ចដំណើរការនីតិវិធីជំនុំជម្រះអាចត្រូវរងផលប៉ះពាល់ដោយសារមានអត្ថិភាពនៃសេចក្តីសម្រេចដែលរកឃើញថា មានភាពលម្អៀងតាមការគិតឃើញ។

53. នៅក្នុងករណីបច្ចុប្បន្ននេះ គ្មានយុត្តិកម្មបែបនេះ ដែលទាមទារឱ្យមានសេចក្តីសម្រេចលើសំណើទៅតាមអង្គសេចក្តីរបស់សំណើឡើយ។ បញ្ហាដែលបានលើកឡើងក្នុងសំណើ គឺដូចគ្នាបេះបិទទៅនឹង

---

(ឯកសារភ្ជាប់ ៣)។ តុលាការព្រហ្មទណ្ឌអន្តរជាតិ *រដ្ឋអាជ្ញា តទល់នឹង Germain Katanga និង Mathieu Ngudjolo Chui* សាលដីកាបណ្តឹងសាទុក្ខរបស់លោក Katanga ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ដែលមានចំណងជើងថា "សេចក្តីសម្រេចលើសារណារបស់មេធាវីការពារក្តី Germain Katanga ស្តីពីការប្រកាសពីការផ្អាកកិច្ចដំណើរការនីតិវិធី និងការឃុំខ្លួនដោយខុសច្បាប់ ICC-01/04-01/07-2259 ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៦-៤៧ (ឯកសារភ្ជាប់ ៤)។

សំណើដែលត្រូវបានសម្រេចយ៉ាងលម្អិតរួចហើយ នៅក្នុងសេចក្តីសម្រេចលើបណ្តឹងជិតចិត្តអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥។

## *ឃ. ផលប្រយោជន៍យុត្តិធម៌ ទាមទារឱ្យអនុវត្តវិធាននីតិវិធីជាធរមាន*

54. វិធាននីតិវិធីដែលតម្រូវឱ្យភាគីដាក់ឯកសារឱ្យទាន់ពេលវេលា គឺជាកត្តាមូលដ្ឋានសម្រាប់ការអនុវត្តដោយយុត្តិធម៌នូវកិច្ចដំណើរការនីតិវិធី ហើយគួរត្រូវបានរក្សាទុក លើកលែងតែមានស្ថានសម្រាលត្រូវបានបង្ហាញឡើង។ ដូចដែលតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្សបានពន្យល់ វិធានទាក់ទងនឹងការកម្រិតកំណត់ពេលវេលានៅក្នុងកិច្ចដំណើរការនីតិវិធី៖

> ...មានគោលដៅក្នុងការធានាដល់រដ្ឋបាលយុត្តិធម៌ និងការគោរពតាម ជាពិសេសសម្រាប់គោលការណ៍សុវត្ថិភាពគតិយុត្តិ។ គូភាគីនៃរឿងក្តីគួរតែរំពឹងដឹងអំពី វិធានទាំងអស់នោះដែលត្រូវអនុវត្ត[45]។

55. ការច្រានចោលញត្តិដែលយឺតយ៉ាវរបស់មេធាវីការពារក្តី ថាមិនអាចទទួលយកបាន មិនត្រឹមតែអាចធ្វើទៅបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានានូវការអនុវត្តកិច្ចដំណើរការនីតិវិធីដោយឆាប់រហ័ស និងយុត្តិធម៌[46]។ ការសម្រេចនាពេលថ្មីៗនេះរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចំពោះបញ្ហាបែបនេះ ដោយបញ្ជាក់ថា "ភារកិច្ចក្នុងការបំពេញកិច្ចក្នុងលក្ខណៈប្រុងប្រយ័ត្ន និងឆាប់រហ័ស ត្រូវអនុវត្តចំពោះគ្រប់ភាគីដែលចូលរួមពាក់ព័ន្ធក្នុងកិច្ចដំណើរការនីតិវិធី រួមទាំងជនជាប់ចោទ"[47] ស្របគ្នាទាំងស្រុងជាមួយលក្ខខណ្ឌតម្រូវឱ្យមានភាពឆាប់រហ័ស ដែលត្រូវ

---

[45] ECtHR *Miragell Escolano និងអ្នកដទៃទៀត តទល់នឹងប្រទេសអេស្ប៉ាញ* សាលក្រមថ្ងៃទី២៥ ខែមករា ឆ្នាំ២០០០ បណ្តឹងលេខ 38366/97, 38688/97, 40777/98, 40843/98, 41015/98, 41446/98, 41484/98, 41487/98 និង 41509/98 កថាខណ្ឌ ៣៣ (ឯកសារភ្ជាប់ ៥)។

[46] តុលាការព្រហ្មទណ្ឌអន្តរជាតិ *រដ្ឋអាជ្ញា តទល់នឹង Dominic Ongwen*, សាលដីកាបណ្តឹងសាទុក្ខរបស់លោក Dominic Ongwen ប្រឆាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង IX "សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ដែលចោទប្រកាន់អំពីកំហុសឆ្គង នៅក្នុងសេចក្តីសម្រេចគាំទ្រ" ICC-02/04-01/15-1562 ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ កថាខណ្ឌ ១៣១-១៣៦។

[47] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៥២។

អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក[48] និងក្តីបារម្ភដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចលើបណ្តឹងជំទាស់អង្គជំនុំជម្រះសាលាដំបូង[49]។

56. តាមពិតទៅ ការណ៍ដែលថា សេចក្តីសម្រេចលើបណ្តឹងជំទាស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធជាមួយនឹងអង្គសេចក្តីនៃសំណើសុំប្តឹងជំទាស់ដែលយឺតយ៉ាវ គឺ "ដើម្បីប្រយោជន៍យុត្តិធម៌" អាចជំរុញដល់មេធាវីការពារក្តីឱ្យលែងគិតពិចារណាទៅលើការចែងក្នុងវិធាន ៣៤ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៅក្នុងករណីបច្ចុប្បន្ននេះ។ នាពេលនេះ អង្គជំនុំជម្រះតុលាការកំពូលគួរតែអនុវត្តដោយម៉ឺងម៉ាត់ ដើម្បីពង្រឹងវិធាននីតិវិធី ដែលការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបានសច្ចភាពយុត្តិធម៌ និងកិច្ចដំណើរការនីតិវិធីដែលឆាប់រហ័ស។

## IV. សំណើរបស់មេធាវីការពារក្តីសុំឱ្យមានសវនាការ

57. សំណើរបស់មេធាវីការពារក្តីសុំឱ្យមានសវនាការ គួរត្រូវបានបដិសេធចោល។ វិធាន ៣៤ នៃវិធានផ្ទៃក្នុង មិនបានចែងអំពីសវនាការផ្ទាល់មាត់ក្នុងការសម្រេចលើសំណើសុំប្តឹងជំទាស់ឡើយ។ ទោះបីជាអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការសម្រេចលើនីតិវិធីក្តី ប៉ុន្តែ មិនមានហេតុផលអ្វីដែលថា សវនាការអាចជួយដល់ការសម្រេចលើបញ្ហានេះឡើយ។ សវនាការបែបនេះគ្រាន់តែធ្វើឱ្យមានការខាតបង់ពេលវេលា និងធនធានបន្ថែម ដោយមិនមានភាពចាំបាច់ទាល់តែសោះ។ ដូច្នេះសំណើនេះគួរត្រូវបានបដិសេធ។

## V. សំណើ

58. ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំដោយក្តីគោរព ដល់អង្គជំនុំជម្រះតុលាការកំពូល ថា៖

(១) **ច្រានចោល** សំណើរបស់លោក ខៀវ សំផន សុំប្តឹងជំទាស់ទៅក្រុមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូល ដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១ ដោយថាមិនអាចទទួលយកបាន។

---

[48] មាត្រា ៣៣ថ្មី និងមាត្រា ៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ ឯកសារ **F49** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់ សារណាបណ្តឹងសាទុក្ខ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ កថាខណ្ឌ ១៩។

[49] ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៣២។

(២) **ច្រានចោល** សំណើសុំឱ្យមានសវនាការផ្ទាល់មាត់នេះ។

ដោយសេចក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ | ពេជ្រ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Megan HIRST<br>សហមេធាវីនាំមុខ | ឡុងដ៍ | |